ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍

# សេចក្តីប្រកាសព័ត៌មាន

## ឯកឧត្តម ត្រាំ អ៊ីវតឹក
## រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ដឹកនាំគណៈប្រតិភូអញ្ជើញ
## ចូលរួមវេទិកាថ្នាក់រដ្ឋមន្ត្រីបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន ឆ្នាំ២០១៦
## នៅប្រទេសសិង្ហបុរី

តបតាមការអញ្ជើញរបស់ឯកឧត្តមបណ្ឌិត **YAACOB IBRAHIM** រដ្ឋមន្ត្រីក្រសួងគមនាគមន៍ និងព័ត៌មានសិង្ហបុរី **ឯកឧត្តម ត្រាំ អ៊ីវតឹក រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍** បានដឹកនាំគណៈប្រតិភូអញ្ជើញចូលរួមពិធីបើក **"ពិព័រណ៍ផ្លាស់ប្តូរធុរកិច្ចបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន"** និង **"វេទិកាថ្នាក់រដ្ឋមន្ត្រីបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន ឆ្នាំ២០១៦"** ដែលនឹងប្រារព្ធធ្វើឡើងចាប់ពីថ្ងៃទី៣០ ដល់ថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០១៦ នៅប្រទេសសិង្ហបុរី ។

ព្រឹត្តិការណ៍ប្រចាំឆ្នាំនេះ គឺជាវេទិកាស្តីពីបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មានដ៏ធំមួយនៅក្នុងតំបន់ដែលបានរៀបចំឡើងដោយក្រសួងគមនាគមន៍ និងព័ត៌មានសិង្ហបុរី ព្រមទាំងមានការអញ្ជើញចូលរួមពីរដ្ឋមន្ត្រីទទួលបន្ទុកវិស័យបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន អ្នករៀបចំគោលនយោបាយសហភាពទូរគមនាគមន៍អន្តរជាតិ (ITU) និងផ្នែកឯកជនពាក់ព័ន្ធ ដើម្បីពិភាក្សារិះរកចំណុចគន្លឹះល្អៗកាត់បន្ថយគម្លាតអភិវឌ្ឍ បង្កើនកិច្ចសហប្រតិបត្តិការ និងចែករំលែកឧត្តមានុវត្តនៅក្នុងតំបន់រួមវិភាគទានខាងស្មារតីក្នុងការដោះស្រាយបញ្ហាប្រឈម និងពង្រឹងសមត្ថភាពស្រូបទាញប្រយោជន៍ពីកាលានុវត្តភាពថ្មី ក្នុងបរិបទដែលអន្តរកម្មតាមប្រព័ន្ធបច្ចេកវិទ្យាកាន់តែមានសន្ទុះ និងដើរតួនាទីយ៉ាងសំខាន់នៅគ្រប់ ទិដ្ឋភាព។

ប្រធានបទសម្រាប់វេទិកាដ៏មានអត្ថន័យនេះគឺផ្តោតលើ ***"ការតភ្ជាប់មាតិកា និងសន្តិសុខតាមប្រព័ន្ធបច្ចេកវិទ្យា"*** ដែលសុទ្ធតែជាធាតុផ្សំដ៏សំខាន់នៃយុគសម័យអ៊ីនធឺណិត (Internet of Thing) និងនិម្មាបនកម្មបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន (ICT Architecture)។

រាជធានីភ្នំពេញ, ថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០១៦

កាច់ជ្រុងវិថីលេខ១៣និង១០២សង្កាត់វត្តភ្នំខណ្ឌដូនពេញ
ទូរស័ព្ទ (៨៥៥) ២៣-៧២៤៨០៩/៤២៨២៤៦
ទូរសារ (៨៥៥) ២៣-៤២៦៥៤១/៤២៦០០៥/៧២៤៨០៩